# ជម្រើសសម្រាប់ថ្ងៃអាទិត្យ

*« តើពិធីសាក្រាម៉ង់គឺជាអ្វី ? » អានីតា បានសួរ ។*





ដោយ រ៉ឺបិកកា ដេកមេន
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេស អ៊ីស្លង់ ។*

« ខ្ពស់ជាងនេះ ! » អ៊ីវ៉ូលេត បាននិយាយទៅកាន់មិត្តរបស់នាងឈ្មោះ អានីតា ។ ពួកគេចាំមើលតើពួកគេអាចលោតលើបន្ទះក្រណាត់រ៉ឺស័ររបស់ អ៊ីវ៉ូលេត បានខ្ពស់ប៉ុណ្ណា ។

រំពេចនោះ អានីតាបានលោតឡើងយ៉ាងខ្ពស់ណាស់ ។ ពេលជើងនាងលោតចុះម្តងទៀត វាធ្វើអោយអ៊ីវ៉ូលេតហោះឡើង ! ក្មេងស្រីទាំងពីរបានទង្គិចគ្នាធ្លាក់ទៅលើបន្ទះក្រណាត់រ៉ឺស័រ ។ ពួកគេសើចសប្បាយ ។

អានីតានិយាយថា « វាសប្បាយណាស់ » ។ « តើយើងអាចលេងនៅថ្ងៃស្អែកទៀតទេ ? »

អ៊ីវ៉ូលេតផ្តួលខ្លួននាងទៅក្រោយ ។ « ត្រូវហើយ ! ខ្ញុំក៏ចូលចិត្តលេងដែរ » ។

«យើងអាចលេងនៅផ្ទះលោកយាយរបស់ខ្ញុំបាន » ។ ផ្ទះលោកយាយរបស់អានីតា នៅឃ្លាតតែពីរបីផ្ទះពីអ៊ីវ៉ូលេតប៉ុណ្ណោះ ។

បន្ទាប់មក អ៊ីវ៉ូលេតបានចាំថាថ្ងៃស្អែកគឺជាថ្ងៃអាទិត្យ ។ នាងចង់ទៅអង្គការបឋមសិក្សា ។ វានឹងសប្បាយរីករាយក្នុងការលេងជាមួយអានីតា ប៉ុន្តែនាងចង់ធ្វើការជ្រើសរើសដ៏ល្អមួយ ។

អ៊ីវ៉ូលេតបាននិយាយថា « ខ្ញុំទើបនឹកឃើញថាខ្ញុំមិនអាចមកលេងបានទេ » ។ « ខ្ញុំសូមទោស ។ ថ្ងៃស្អែកខ្ញុំនឹងទៅព្រះវិហារជាមួយគ្រួសាររបស់ខ្ញុំ » ។

អានីតាបានក្រោកឈរឡើង ហើយលោតម្តងទៀត ។ « ហេតុអ្វី ? »

អ៊ីវ៉ូលេតបានចាប់ផ្តើមលោតដែរ ។ « មែនហើយ ខ្ញុំចង់ធ្វើតាមព្រះយេស៊ូវគ្រីស្ទ » ។ គ្រួសាររបស់ខ្ញុំទៅព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ ដើម្បីរៀនអំពីទ្រង់ ហើយទទួលទានសាក្រាម៉ង់ » ។

« តើពិធីសាក្រាម៉ង់គឺជាអ្វី ? » អានីតា បានសួរ ។

អ៊ីវ៉ូលេតបាននិយាយថា « ពិធីសាក្រាម៉ង់នោះ គឺនៅពេលដែលយើងទទួលទាននំប៉័ងមួយដុំតូច និងទឹកមួយកូនពែងតូច ដើម្បីជាការចងចាំដល់ព្រះយេស៊ូវគ្រីស្ទ » ។ « បន្ទាប់មកសមាជិកឡើងនិយាយអំពីរបៀបដែលព្រះយេស៊ូវជួយពួកគេ ។ ហើយបន្ទាប់ពីនោះក៏មានថ្នាក់ពិសេសសម្រាប់ក្មេងៗផងដែរ ! »

« ស្តាប់ទៅសប្បាយណាស់ ! » អានីតា បាននិយាយថា « តើខ្ញុំអាចទៅបានទេ ? »

« ប្រាកដជាបាន ! » អ៊ីវ៉ូលេតបានញញឹម ។



អានីតាបានរត់ត្រឡប់ទៅផ្ទះវិញដើម្បីសុំលោកយាយរបស់នាង ប្រសិនបើនាងអាចទៅព្រះវិហារជាមួយអ៊ីវ៉ូលេតបានឬទេ ។ នៅព្រឹកស្អែក អេវ៉ូលេត និងគ្រួសាររបស់នាងបានមកទទួលអានីតានៅតាមផ្លូវទៅព្រះវិហាររបស់ពួកគេ ។

នៅពេលដែលពួកគេទៅដល់ព្រះវិហារ អ៊ីវ៉ូលេតបាននាំអានីតាដើរមើលជុំវិញព្រះវិហារ ។ នាងបានបង្ហាញបន្ទប់អង្គការបឋមសិក្សា កន្លែងហាត់ប្រាណ និងសាលជំនុំ ។

មិនយូរប៉ុន្មានដល់ពេលប្រជុំសាក្រាម៉ង់ហើយ ។ អ៊ីវ៉ូលេត និង អានីតា អង្គុយជាមួយគ្នា ។ អ៊ីវ៉ូលេតបានព្យាយាមគិតអំពីព្រះយេស៊ូវគ្រីស្ទក្នុងអំឡុងពេលប្រជុំសាក្រាម៉ង់ ។ បន្ទាប់មកពួកគេបានស្តាប់អ្នកឡើងនិយាយ ។

នៅទីបំផុត វាដល់ពេលសម្រាប់អង្គការបឋមសិក្សាហើយ ! អ៊ីវ៉ូលេតបានណែនាំអានីតា ឲ្យស្គាល់មិត្តភក្តិមួយចំនួនរបស់នាង ។

អ៊ីវ៉ូលេតបាននិយាយថា « នេះគឺជាមិត្តរបស់ខ្ញុំឈ្មោះ អានីតា » ។

អ្នកគ្រូបង្រៀនអង្គការបឋមសិក្សានិយាយថា « យើងសប្បាយចិត្តណាស់ដែលប្អូនមកថ្ងៃនេះ ។ ខ្ញុំ ស៊ីស្ទើរ ម៉ាក់នូសសិន » ។

នៅពេលដែលអ៊ីវ៉ូលេត និងអានីតាបានស្តាប់មេរៀនអំពីព្រះយេស៊ូវគ្រីស្ទ អ៊ីវ៉ូលេតមានអារម្មណ៍សប្បាយរីករាយក្នុងចិត្ត ។ នាងចូលចិត្តនៅព្រះវិហារជាមួយអានីតា ។ នាងបានបែរទៅរកអានីតា ហើយញញឹម ។ មិត្តរបស់នាងញញឹមដាក់នាងវិញ ។

អានីតាបាននិយាយនៅតាមផ្លូវត្រឡប់មកផ្ទះវិញថា « អរគុណដែលបានអញ្ជើញខ្ញុំមក » ។

អ៊ីវ៉ូលេតរីករាយណាស់ដែលនាងអាចធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ ហើយនាងសប្បាយចិត្ត ដែលអានីតាចង់រៀនអំពីទ្រង់ផងដែរ ។

វាសប្បាយរីករាយក្នុងការលោតលើបន្ទះក្រណាត់រ៉ឺស័រ និងហោះទៅលើ ប៉ុន្តែអារម្មណ៍កក់ក្តៅដែលអ៊ីវ៉ូលេតមានគឺកាន់តែប្រសើរជាង ។●









តើប្អូនអាចអញ្ជើញនរណាម្នាក់ទៅព្រះវិហារជាមួយប្អូនបានទេ ?

